**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពីការយឺតយ៉ាវក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹង**
**ការកើនឡើងនៃចំណូល ចំណេញប្រតិបត្តិការ និងចំណេញសុទ្ធ**
**នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២១**

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) សូមជម្រាបជូនវិនិយោគិន និងសាធារណជនជ្រាបថា រ.ទ.ស.ភ មានកាតព្វកិច្ច ត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការកើនឡើងនៃចំណូល ៣៣,១៤% ចំណេញប្រតិបត្តិការ ៧៣,៦៣% និងចំណេញសុទ្ធ ១២០,១១% ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០ របស់ខ្លួន យ៉ាងយូរ១ម៉ោង មុនម៉ោងអនុវត្តការជួញដូរ នៅថ្ងៃបន្ទាប់ពីហេតុការណ៍ខាងលើ បានកើតឡើង។ ប៉ុន្តែ រ.ទ.ស.ភ បានធ្វើការផ្សព្វផ្សាយព័ត៌មានខាងលើជូនសាធារណជនយឺតយ៉ាវ ដោយសារមន្ត្រីទទួលបន្ទុកក្នុងការរៀបចំនូវ ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលសម្រាប់ត្រីមាស និងរយៈពេល៩ខែ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ មានវិជ្ជមាន កូវីដ-១៩។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទទួលជ្រាប។

ថ្ងៃ ចន្ទ ១រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០២១
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ:(៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh